# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីប្រចាំខែតុលា



លេខ ២៧៦ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 276 Volume 23 Before Christ 2567 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី១១ នីតិកាលទី៤ ........ ១
- ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ ..... ៣
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១១ នីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ........ ៤
- សម្តេចប្រមុខរដ្ឋស្តីទីទទួលជួបសវនាការជាមួយនាយករដ្ឋមន្ត្រីថៃ ........ ៦
- សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធិវង្ស ........ ៨
- ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ នៅវត្តប្រាសាទនាងខ្មៅ និងវត្តប្រាំបីមុំ ........ ១០
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ១២


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តកំពត និងខេត្តកែប ........ ១៤
- គណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញឈ្វេងយល់អំពីវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន នៅខេត្តសៀមរាប ........ ១៦
- ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១១ នៅវត្តចំនួន៥ ក្នុងឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង........ ១៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ១៩
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨........ ២៣
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៣៤
- ការងារទទួលពាក្យបណ្តឹង........ ៣៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៣៥


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងកំណត់ទិសដៅការងារខែតុលា ឆ្នាំ២០២៣ ........ ៣៦
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំនព្វមាស និងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២៣........ ៣៨
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញស្តីពីសភាបៃតង៖ តួនាទីសំខាន់របស់រដ្ឋបាលសភា........ ៣៩
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៤០



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម គឹម ពិសិដ្ឋ
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោក ធុន គីមជី
លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធិវង្ស ស្ថិតក្នុងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម សេដ្ឋា ថាវីស៊ីន៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

## ព្រឹទ្ធសភាបើកសម័យប្រជុំលើកទី១១ នីតិកាលទី៤



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំបើកសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤*

នាព្រឹកថ្ងៃចន្ទ ទី២ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំលើកទី១១ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៨រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈតែមួយគឺ៖ ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១០ និងលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤ ។

ក្នុងអំឡុងពេលចន្លោះសម័យប្រជុំព្រឹទ្ធសភាបីខែ (៣០/-០៦/២០២៣-៣០/០៩/២០២៣) ថ្នាក់ដឹកនាំ គណៈ-កម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមភូមិភាគនានា ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានរួមគ្នាខិតខំបំពេញភារកិច្ចរៀងៗខ្លួន ហើយសម្រេចបានលទ្ធផលផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិ និងប្រជា-ពលរដ្ឋ។

សកម្មភាពលេចធ្លោ គឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋានរបស់ថ្នាក់ដឹកនាំ និងសមាជិក សមា-ជិកាព្រឹទ្ធសភា ដើម្បីជួយសម្រួលប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត ដោះស្រាយសំណូមពរនិងបញ្ហាប្រឈម-នានា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។ គណៈកម្មការទាំង១០ និងក្រុម-នានារបស់ព្រឹទ្ធសភា ដែលជាសេនាធិការរបស់ព្រឹទ្ធសភា បានចុះជួបពិភាក្សាការងារជាមួយនឹងក្រសួង-ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍន-ភាពការងារតាមវិស័យ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការ



*ទិដ្ឋភាពសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤*





*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ឡើងអានរបាយការណ៍សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា*

ល្អជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ជាពិសេសជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតួអង្គសំខាន់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

តាមរយៈដំណើរបេសកកម្មទៅកាន់មូលដ្ឋាន ព្រឹទ្ធសភាសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផល និងសមិទ្ធផលថ្មីៗបន្ថែមទៀតក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច លើគ្រប់វិស័យដែលរាជរដ្ឋាភិបាលខិតខំសម្រេចបានក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសេដ្ឋកិច្ចជាតិបន្តមានកំណើនវិជ្ជមាន ដើម្បីពង្រឹងពង្រីកគោលនយោបាយគាំពារសង្គម ដោយធានាបាននូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទាំងប្រទេស។ ជារួមរាជរដ្ឋាភិបាលបានបន្តជំរុញអនុវត្តន៍ដោយសកម្មនូវរាល់កំណែទម្រង់រដ្ឋស៊ីជម្រៅរបស់ខ្លួនលើគ្រប់វិស័យដោយប្រកាន់យកអភិបាលកិច្ចល្អជាស្នូល។ ដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹងពង្រីកឥតឈប់ឈរ និងកំពុងបន្តទៅមុខដោយរលូនតាមគន្លងនីតិរដ្ឋ ដោយឆ្លុះបញ្ចាំងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅ។

ស្របតាមជំហានទៅមុខដ៏ស្វាហាប់ និងភាពទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ព្រឹទ្ធសភាសូមគាំទ្រ និងលើកទឹកចិត្តរាជរដ្ឋាភិបាលក្នុងការបង្កើនសកម្មភាពដោះស្រាយបញ្ហាដែលនៅសេសសល់ ដើម្បីពន្លឿនសន្ទុះរីកចម្រើនសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន។

ឆ្លៀតក្នុងឱកាសនេះ ព្រឹទ្ធសភាសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រដ៏ថ្លៃថ្លាពីគ្រប់មជ្ឈដ្ឋានដៃគូនានានិងគ្រប់ស្ថាប័នជាតិដែលញុំាងឱ្យព្រឹទ្ធសភាដំណើរការទៅមុខដោយរលូន៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤*

# ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន០២




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃចន្ទ ទី១៦ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០ នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន០២រួមមាន៖

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការ-សាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាស-ចរណ៍ស៊ីវិលទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤។

២-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤ ។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការ-អចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃអង្គារ ទី១៧ ខែ-តុលា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្ត-សម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤ ដោយមានរបៀបវារៈតែមួយគត់គឺ៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)




*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១១ នីតិកាលទី៤ ដើម្បីពិនិត្យ ហើយឱ្យយោបល់ លើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំការបន្តសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤*

នាព្រឹកថ្ងៃអង្គារ ទី១៧ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី១១ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈតែមួយគត់គឺ៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

ក្នុងឱកាសនោះ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់នេះថា សេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល តាក់តែងឡើងជំនួសច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ឆ្នាំ១៩៩៦ ក្នុងគោលបំណងលើកកម្ពស់ និងធានាដល់ដំណើរការគ្រប់គ្រង ចាត់ចែង និងអភិវឌ្ឍន៍វិស័យអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមស្ថានភាពវិវឌ្ឍនៅព្រះរាជាណាចក្រកម្ពុជា ដែលកំពុងមានការរីកចម្រើន និងការប្រែប្រួលខាងបច្ចេកវិទ្យាអាកាសចរណ៍ស៊ីវិលកាន់តែទំនើប និងស៊ីជម្រៅរួមទាំងរចនាសម្ព័ន្ធគ្រប់គ្រងផងដែរ ជាពិសេស ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌ





*ទិដ្ឋភាពសម័យប្រជុំលើកទី១១ ព្រឹទ្ធសភានីតិកាលទី៤*





*ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍*

តម្រូវបន្ថែមមួយចំនួន ក្នុងនាមជាសមាជិក នៃអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO)។

សេចក្ដីព្រាងច្បាប់នេះ ដើរតួនាទី និងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើតការងារដោយផ្ទាល់ និងដោយប្រយោល ការគាំទ្រ និងជំរុញវិស័យ ទេសចរណ៍ ពាណិជ្ជកម្ម ការទាក់ទាញ និងជំរុញដល់ការវិនិយោគផ្ទាល់ពីបរទេស និងធុរកិច្ចក្នុងស្រុកប្រកបដោយទំនុកចិត្ត និងមានលក្ខណៈសេដ្ឋកិច្ច។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន ១១មាត្រា និងត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន ១០១សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧។

ក្រោយពីសមាជិកព្រឹទ្ធសភា បានឡើងមានយោបល់ និងលើកជាសំណួររួចមក ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បានឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)







*សមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តច្បាប់*

# សម្ដេចប្រមុខរដ្ឋស្ដីទីទទួលជួបសវនាការជាមួយនាយករដ្ឋមន្ត្រីថៃ



*ឯកឧត្តម សេដ្ឋា ថាវីស៊ីន និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១៦:២០ នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបឯកឧត្តម **សេដ្ឋា ថាវីស៊ីន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ នៅវិមានព្រឹទ្ធសភា ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងព្រះបរមនាមព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រមុខរដ្ឋស្ដីទីបានសម្ដែងនូវការស្វាគមន៍យ៉ាងស្មោះស្ម័គ្របំផុតចំពោះឯកឧត្តម **សេដ្ឋា ថាវីស៊ីន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ ដែលបានដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រមុខរដ្ឋស្ដីទីបានថ្លែងអំណរគុណចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី ដែលបានជ្រើសរើសប្រទេសកម្ពុជាជាប្រទេសដំបូងសម្រាប់បំពេញទស្សនកិច្ចជាផ្លូវការ។

ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅកម្ពុជានាឱកាសនោះបានឆ្លុះបញ្ចាំងពីសារសំខាន់ និងការយកចិត្តទុកដាក់ខ្ពស់ដល់ការថែរក្សាពូនជ្រំចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការជាប្រពៃណីដ៏ល្អដែលមានស្រាប់រវាងប្រជាជន និងប្រទេសទាំងពីរឱ្យបានកាន់តែរឹងមាំស៊ីជម្រៅថែមទៀត ដើម្បីបម្រើផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមកទាំងពេលបច្ចុប្បន្ន និងពេលអនាគតសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានសម្ដែងនូវការអបអរសាទរចំពោះឯកឧត្តម **សេដ្ឋា ថាវីស៊ីន** ដែលត្រូវបានសភានៃព្រះរាជាណាចក្រថៃ បោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តជ្រើសតាំងជានាយករដ្ឋមន្ត្រីទី៣០ នៃព្រះរាជាណាចក្រថៃ ហើយត្រូវបានព្រះមហាក្សត្រ នៃព្រះរាជាណាចក្រថៃ សព្វព្រះរាជហឫទ័យត្រាស់បង្គាប់តែងតាំងជានាយករដ្ឋមន្ត្រី។

នៅក្នុងឱកាសនោះ ឯកឧត្តម **សេដ្ឋា ថាវីស៊ីន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្ដេចប្រមុខរដ្ឋស្ដីទី ដែលបានចំណាយពេលដ៏មានតម្លៃទទួលជួបឯកឧត្តម និងគណៈប្រតិភូ។ ឯកឧត្តមនាយករដ្ឋមន្ត្រីបានសម្ដែងនូវសេចក្ដីរីករាយដែលបានមកបំពេញទស្សនកិច្ចជាលើកដំបូងនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមសង្ឃឹមថា នាពេលខាងមុខ ប្រទេស និងប្រជាជនទាំងពីរនឹងបង្កើនទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយគ្នាកាន់តែល្អប្រសើរឡើងថែមទៀត។

ឯកឧត្តមនាយករដ្ឋមន្ត្រីថៃ បានជម្រាបជូនសម្ដេចប្រមុខរដ្ឋស្ដីទី អំពីលទ្ធផល នៃជំនួបពិភាក្សារវាងឯកឧត្តមជាមួយនឹងសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងវិស័យការទូត ការវិនិយោគ ការពារជាតិ និងបញ្ហាពលកររបស់ប្រទេសកម្ពុជាដែលបាននឹងកំពុងទៅធ្វើការនៅប្រទេសថៃ ដើម្បីធ្វើយ៉ាងណាឱ្យពលករទាំងនោះទទួលបានការស្នាក់នៅ និងធ្វើការបានកាន់តែងាយស្រួលជាងមុន។

ឯកឧត្តមនាយករដ្ឋមន្ត្រីថៃបានសម្ដែងនូវសេចក្ដីរីករាយដែលព្រះមហាក្សត្រ នៃប្រទេសទាំងពីរមានទំនាក់ទំនងល្អ។ ក្នុងនោះ ព្រះអង្គម្ចាស់ក្សត្រីមហាចក្រី **សារិនថន** បាន




*ទិដ្ឋភាពក្នុងជំនួបសវនាការ*

ផ្ដល់អាហារូបករណ៍ដល់និស្សិតកម្ពុជា បានទៅសិក្សានៅប្រទេសថៃប្រមាណជាង ២ពាន់នាក់។ ឯកឧត្ដមនាយករដ្ឋមន្ដ្រីសង្ឃឹមថា នាពេលអនាគត ការវិនិយោគទុនរវាងប្រទេសទាំងពីរនឹងមានការកើនឡើងច្រើនជាងអ្វីដែលបានគ្រោងទុកនាពេលបច្ចុប្បន្ន។ ជាមួយគ្នានោះ ឯកឧត្ដមមានជំនឿជឿជាក់ថា ចាប់ពីពេលនេះទៅប្រទេសទាំងពីរនឹងមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកាន់តែល្អលើវិស័យឧស្សាហកម្ម សេដ្ឋកិច្ច បច្ចេកវិទ្យា និងវិស័យផ្សេងៗទៀត។

ក្នុងឱកាសដ៏ល្អប្រពៃនោះ សម្ដេចប្រមុខរដ្ឋស្ដីទីបានសម្ដែងនូវសេចក្ដីរីករាយដែលបានទទួលព័ត៌មាន អំពីជោគជ័យ នៃជំនួបពិភាក្សារវាងនាយករដ្ឋមន្ដ្រី នៃប្រទេសទាំងពីរ កាលពីព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។ សម្ដេចមានជំនឿជឿជាក់ថា រាជរដ្ឋាភិបាលថ្មី នៃប្រទេសទាំងពីរនឹងបន្ដយកចិត្តទុកដាក់ថែរក្សាសមិទ្ធផលជាប្រវត្តិសាស្ដ្រ ដែលរាជរដ្ឋាភិបាលមុនៗបានខិតខំសម្រេចបានរួមគ្នានាពេលកន្លងមក។ សម្ដេចបានលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលថ្មី នៃប្រទេសទាំងពីរបន្ដជំរុញ និងសម្របសម្រួលនូវយន្ដការនានាដែលមានស្រាប់ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព ជាពិសេសការផ្លាស់ប្ដូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ឈានទៅសម្រេចគោលដៅទំហំពាណិជ្ជកម្មទ្វេភាគីចំនួន ១៥ប៊ីលានដុល្លារ នៅឆ្នាំ២០២៥។

ជាមួយគ្នានោះ សម្ដេចប្រមុខរដ្ឋស្ដីទីមានជំនឿជឿជាក់ថា រាជរដ្ឋាភិបាលថ្មី នៃប្រទេសទាំងពីរនឹងបន្ដរិះរកនូវយន្ដការថ្មីៗបន្ថែមទៀត ដើម្បីបុព្វហេតុ នៃការរីកចម្រើនរបស់ប្រទេសទាំងពីរ សម្រាប់នាំមកនូវវឌ្ឍនភាព វិបុលភាព សន្ដិភាព ស្ថិរភាពយូរអង្វែងរវាងប្រទេសទាំងពីរ ក៏ដូចជាសម្រាប់តំបន់ និងអន្ដរជាតិ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានពាំនាំមកជូនឯកឧត្ដមនាយករដ្ឋមន្ដ្រីថៃ នូវព្រះរាជបណ្ដាំសាកសួរសុខទុក្ខ និងសេចក្ដីគោរពរាប់អានដ៏ជ្រាលជ្រៅអំពីព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ និងថ្នាក់ដឹកនាំកម្ពុជាទូលថ្វាយព្រះមហាក្សត្រ ព្រះមហាក្សត្រី និងជូនថ្នាក់ដឹកនាំកំពូលគ្រប់លំដាប់ថ្នាក់ នៃព្រះរាជាណាចក្រថៃ។

សម្ដេចប្រមុខរដ្ឋស្ដីទីបានសម្ដែងនូវការកោតសរសើរ និងអបអរសាទរចំពោះការអភិវឌ្ឍផ្នែកសង្គមសេដ្ឋកិច្ចរបស់ប្រទេសថៃ និងសូមប្រសិទ្ធពរជ័យ សិរីមង្គលគ្រប់ប្រការថ្វាយព្រះមហាក្សត្រ និងព្រះមហាក្សត្រី និងថ្នាក់ដឹកនាំជាតិ និងប្រជាជនថៃ ទទួលបាននូវការអភិវឌ្ឍប្រទេសកាន់តែខ្លាំងក្លា ប្រកបដោយវិបុលភាព វឌ្ឍនភាព និងមានកិត្យានុភាពដ៏ខ្ពង់ខ្ពស់នៅលើឆាកអន្ដរជាតិ។

សម្ដេចប្រមុខរដ្ឋស្ដីទី បានប្រសិទ្ធពរជូនចំពោះឯកឧត្ដម **សេដ្ឋា ថាវីស៊ីន** និងគណៈប្រតិភូ សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវជោគជ័យក្នុងដំណើរបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)

# សម្ដេចប្រធានព្រឹទ្ធសភាអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធិវង្ស




*ថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញថ្វាយគ្រឿងសក្ការបូជាទៀន ធូប ផ្កាភ្ញី*

ក្នុងឱកាសពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ដែលជាពិធីបុណ្យប្រពៃណីជាតិរបស់ខ្មែរ នាព្រឹកថ្ងៃអាទិត្យ ២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ឆេព ខន** អនុប្រធានទី២ព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញនាំយកនូវគ្រឿងឧបភោគបរិភោគ ចង្ហាន់បិណ្ឌបាត និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធិវង្ស (វត្តព្រែកញ្ញៅ) ស្ថិតក្នុងសង្កាត់ព្រែកញ្ញៅ ខណ្ឌព្រែកញ្ញៅ រាជធានីភ្នំពេញ។

នាឱកាសដ៏ថ្លៃថ្លានោះ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ឆេព ខន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញថ្វាយនូវគ្រឿងសក្ការបូជា ទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចនមស្ការព្រះរតនត្រ័យ សមាទាននិច្ចសីល និមន្តព្រះសង្ឃសូត្រព្រះធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គល ព្រមទាំងនាំយកចង្ហាន់ ទេយ្យទាន គ្រឿងបរិក្ខាររាប់បាត្រ វេរប្រគេនព្រះសង្ឃ ឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធញាតកាទាំងប្រាំពីរសន្តាន ឥស្សរជន និងយុទ្ធជន ដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសដល់ដួងវិញ្ញាណក្ខន្ធរបស់សម្ដេចអគ្គមហាធម្មពោធិសាល




*ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធិវង្ស*





*សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី២*

**ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** សម្ដេច **ស៊ីសុវត្ថិ ជីវ័នមុនីរ៉ាក្ស** ឯកឧត្តម **នៃ ប៉េណា** និង សមាជិក សមាជិកាព្រឹទ្ធសភាដែលបានទទួលមរណកាលទៅកាន់លោកខាងមុខទៅ ហើយនោះ សូមឱ្យជួបប្រកបតែវិបុលសុខគ្រប់ប្រការ និងទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

ជារៀងរាល់ឆ្នាំ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតែងតែចូលរួមពិធីបុណ្យកាន់បិណ្ឌនៅតាមវត្តអារាមនានាយ៉ាងខ្ជាប់ខ្ជួនតាមគន្លងប្រពៃណីព្រះពុទ្ធសាសនា។

បុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យមួយដែលធំជាងគេនៅក្នុងចំណោមពិធីបុណ្យទាំងអស់ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែ ដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ គ្រប់បងប្អូនកូនចៅ សាច់ញាតិសន្ដានទាំងអស់ ទោះនៅទីជិត ឬទីឆ្ងាយ តែងតែធ្វើដំណើរទៅជួបជុំគ្នា ជាពិសេសឪពុកម្ដាយនៅស្រុកកំណើត ដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃដែលគង់នៅវត្តអារាម។

ពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌឆ្នាំ២០២៣ ប្រព្រឹត្តទៅចាប់ពីថ្ងៃ ១រោច ដល់ថ្ងៃ ១៥រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)



*ថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញរាប់បាត្រ*





*ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុនីប្រសិទ្ធីវង្ស*

# ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ នៅវត្តប្រាសាទនាងខ្មៅ និងវត្តប្រាំបីមុំ





*ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញកាន់បិណ្ឌវេនទី៤ នៅវត្តប្រាសាទនាងខ្មៅ*

នាព្រឹកថ្ងៃ៣ និងថ្ងៃ៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បាន អញ្ជើញនាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៤ នៅវត្តប្រាសាទនាងខ្មៅ ស្ថិតក្នុងឃុំរវៀង ស្រុកសំរោង និងវេនទី៨ នៅវត្តប្រាំបីមុំ ស្ថិតក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។

នាឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានអញ្ជើញថ្វាយនូវគ្រឿងសក្ការបូជាទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចនមស្ការព្រះរតនត្រ័យ សមាទាននិច្ចសីល និមន្តព្រះសង្ឃសូត្រព្រះធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គល ព្រមទាំងនាំយកចង្ហាន់ ទេយ្យទាន គ្រឿងបរិក្ខារ រាប់បាត្រ វេរប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យដែលកើតពីសទ្ធាជ្រះថ្លាទាំងនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធលោកជំទាវ **ឆ្វ ធៀន** ព្រមទាំងញាតកាទាំងប្រាំពីរសន្ដាន ជាពិសេសជូនចំពោះដួងវិញ្ញាណក្ខន្ធអតីតថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា ឥស្សរជន និងយុទ្ធជន ដែលបានពលីជីវិតដើម្បីជាតិមាតុភូមិ សូមទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

ទេយ្យទានគ្រឿងបរិក្ខារផ្សេងៗដែលបាននាំមកប្រគេនដល់វត្តប្រាសាទនាងខ្មៅនាឱកាសនោះ រួមមាន៖ អង្ករ ២តោន មីយើង៥០កេស ទឹកត្រី៥០យួរ ទឹកក្រូច៥០កេស ទឹកស៊ីអ៊ីវ៥០យួរ ត្រីខ២០កេស ឆៃប៉ូវ១០០គីឡូក្រាម សៀងផ្អែម១០០គីឡូក្រាម និងសាច់ជ្រូក៥០០គីឡូក្រាម ព្រមទាំងបច្ច័យប្រគេនដល់ព្រះសង្ឃចំនួន១០លានរៀល





*សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញសូត្រមន្តកាន់បិណ្ឌវេនទី៤*





*សមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញកាន់បិណ្ឌវេនទី៤*

ផងដែរ។

សូមជម្រាបថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺជាពិធីបុណ្យព្រះពុទ្ធសាសនាដ៏សំខាន់មួយ ដែលប្រជាពលរដ្ឋខ្មែរ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា តែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំចាប់ពីថ្ងៃ ១រោច ដល់ថ្ងៃ ១៥រោច ខែភទ្របទ ដោយចែកចេញជាពីរថ្នាក់ ក្នុងនោះចាប់ពីថ្ងៃ ១រោច រហូតដល់ថ្ងៃ ១៤រោច ខែភទ្របទ គឺជាថ្ងៃកាន់បិណ្ឌ និងថ្ងៃ ១៥រោច គឺជាថ្ងៃបុណ្យភ្ជុំបិណ្ឌតែម្ដង។ ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ គ្រប់បងប្អូនកូនចៅសាច់ញាតិសន្ដានទាំងអស់ ទោះនៅទីជិត ឬក៏ទីឆ្ងាយ តែងតែធ្វើដំណើរទៅជួបជុំគ្នា ជាពិសេសជួបឪពុកម្ដាយនៅស្រុកកំណើត ដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃ ដែលគង់នៅវត្តអារាម។

ពិធីបុណ្យភ្ជុំបិណ្ឌរៀបចំឡើងដើម្បីឧទ្ទិសកុសលថ្វាយ-ប្រគេន-ជូនទៅបុព្វការីជន មានអតីតព្រះមហាក្សត្រ មហាក្សត្រិយានី ព្រះគ្រូឧបជ្ឈាយាចារ្យ ជីដូន ជីតា មាតាបិតា ដែលទ្រង់បានសោយព្រះទីវង្គត អនិច្ចធម្ម និងធ្វើមរណកាលទៅហើយ ដល់វីរជន និងយុទ្ធជន ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ និងដើម្បីឱ្យកូនខ្មែរបានបំពេញនូវបុណ្យកុសល៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)



*ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន និងសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញរាប់បាត្រ*





*ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន និងក្រុមគ្រួសារ អញ្ជើញកាន់បិណ្ឌវេនទី៨នៅវត្តប្រាំបីមុំ*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្វាយព្រះរាជវន្ទនកិច្ចទទួលព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់មាតុប្រទេសវិញ។



❈នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសកគង់ ខាត់បិតាក្មេករបស់សម្តេច ញាតកាទាំង៧សន្តាន និងបុព្វការីជន នៅវត្តសុវណ្ណគិរីជើងផ្នូក ភូមិជើងផ្នូក ឃុំត្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។



❈នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីអបអរសាទរទិវារំលឹកខួប៣០ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បុត្រាបុត្រី ព្រមទាំងបងប្អូនទាំងអស់ក្នុងភូមិកំណើតរបស់សម្តេច (ភូមិកណ្តាលកោះ) បានចូលរួមប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតកាទាំង៧សន្តាន នៅឃុំកោះសូទិន ខេត្តកំពង់ចាម។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹង ប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បានអញ្ជើញប្រារព្ធពិធីបង្សុកូលជូនដល់វិញ្ញាណក្ខន្ធមាតា បិតា ញាតកាទាំង៧សន្ដាន នៅវត្តនាគវ័ន្ដ ស្ថិតក្នុងសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសួរសុខទុក្ខលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យ អែរ ផ្លឺស ស្ថិតក្នុងសង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកា **ផ្លេក គិរុណា** នៅប្រាង្គចេតិយមហាឧបាសិកា ក្នុងបរិវេណវត្តសុគន្ធមានបុណ្យ ស្ថិតក្នុងភូមិម្លូម៉ឺន ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល។



❈នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវបានអញ្ជើញនាំយកនូវទេយ្យវត្ថុ គ្រឿងឧបភោគបរិភោគ រួមនឹងបច្ច័យមួយចំនួន ប្រគេនដល់ព្រះសង្ឃ អាចារ្យ គណៈកម្មការ និងពុទ្ធបរិស័ទ ក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ ចំនួន២វត្ត គឺនៅវត្តទេពនិម្មិត (ហៅវត្តអញ្ចាញ) ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ និងវត្តពង្ររង្សី (ហៅវត្តជ្រៃម្រាក់) ស្ថិតក្នុងឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។



❈នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា អញ្ជើញថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ “ព្រះបរមរតនកោដ្ឋ” នៅមណ្ឌបតម្កល់ព្រះបរមរូប ជិតវិមានឯករាជ្យ រាជធានីភ្នំពេញ៕



# គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់ និងប្រមូលព័ត៌មាន ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តកំពត និងខេត្តកែប



*លោកជំទាវ មាន សំអាន ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា*

ក្នុងអំឡុងពេល នៃចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី១០ និងទី១១ គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ សំខាន់ផ្ដោតលើការផ្ដល់សេវាបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការគ្រប់គ្រងថែទាំកុមារ នៅខេត្តកំពត និងខេត្តកែប កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣។

ក្នុងដំណើរបំពេញបេសកកម្មនេះ នៅព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារ និងសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាខេត្ត អាជ្ញាធរខេត្តកំពត ដឹកនាំដោយឯកឧត្តម **ម៉ៅ ធនិន** អភិបាល នៃគណៈអភិបាលខេត្តកំពត ស្ដីពីការផ្ដល់សេវាបណ្ដុះណ្ដាលវិជ្ជាជីវៈ និងការគ្រប់គ្រងថែទាំកុមារ នៅសាលាខេត្តកំពត។ ក្នុងឱកាសនោះ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានសម្ដែងនូវការអបអរសាទរចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរបស់អាជ្ញាធរខេត្តកំពត នាពេលកន្លងមក ដែលទទួលបានការគាំទ្រពីប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋនៅទូទាំងប្រទេស។ លោកជំទាវបានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងបំពេញការងារតាមតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ ធ្វើឱ្យខេត្តមានការរីកចម្រើនជាបន្តបន្ទាប់លើគ្រប់វិស័យ។ ជាមួយគ្នានោះ លោកជំទាវបានអំពាវនាវ ជំរុញ និងលើកទឹកចិត្តឱ្យថ្នាក់ដឹកនាំខេត្តបន្តចុះដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបន្តទៀត ដើម្បីចូលរួមបញ្ចប់វិវាទ ក៏ដូចជាកាត់បន្ថយការចំណាយថវិកា និងពេលវេលារបស់ប្រជាពលរដ្ឋផងដែរ។

ក្រៅពីនេះត្រូវបន្តការយកចិត្តទុកដាក់ការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល បន្តដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្តការអភិវឌ្ឍនៅទូទាំងខេត្តឱ្យមានការរីកចម្រើនបន្ថែមទៀត ជាពិសេសត្រូវយកចិត្តទុកដាក់លើអតីតយុទ្ធជនចូលនិវត្តន៍ ជួយដោះស្រាយរាល់បញ្ហាទាំងឡាយរបស់មន្ទីរជំនាញ បន្តចូលរួមថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ បន្តផ្ដល់សេវារដ្ឋបាលសាធារណៈជូន





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សា និងអាជ្ញាធរខេត្តកំពត*





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ជួបសំណេះសំណាលជាមួយគណៈគ្រប់គ្រង នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត*

ប្រជាពលរដ្ឋឱ្យទាន់ពេលវេលា។ ដោយឡែកចំពោះបញ្ហាប្រឈម និងសំណូមពរនានា ដែលអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធបានលើកឡើង ហើយអាជ្ញាធរខេត្តពុំអាចដោះស្រាយបាន គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា នឹងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរកវិធានការដោះស្រាយឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

បន្ទាប់មកនៅរសៀលថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញទស្សនកិច្ច និងជួបសំណេះសំណាលជាមួយនឹងគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកស្ម័គ្រចិត្ត នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត ខេត្តកំពត ព្រមទាំងបាននាំយកអំពូលភ្លើង និងបន្ទះសូឡា ( Solar light IP67 500W) ចំនួន២០គ្រឿង និងឧបត្ថម្ភថវិកាចំនួន៤លានរៀល ជូនដល់វិទ្យាស្ថាន។

ដោយឡែកនៅព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ អមដំណើរដោយលោកអភិបាលរងខេត្តកែប និងមន្ត្រីមន្ទីរជំនាញពាក់ព័ន្ធ បានអញ្ជើញចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយនឹងកុមារកំព្រា នៅមជ្ឈមណ្ឌលបុរីកុមារខេត្តកែប ដើម្បីពិនិត្យមើលការអប់រំ និងការគ្រប់គ្រងថែទាំកុមារ។

ក្នុងឱកាសនោះ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បាននាំយកអំណោយ និងថវិកាជូនមជ្ឈមណ្ឌលបុរីកុមារខេត្តកែបរួមមាន៖ ម៉ូតូកង់បីចំនួន១គ្រឿង អង្ករ៥បាវ ទម្ងន់២៥០គីឡូក្រាម សៀវភៅ២កេស (៤០០ក្បាល) មី១កេសធំ ត្រីខកំប៉ុង១កេសធំ (១០យួរ) ប្រេងឆា១ធុង ចំណុះ២០លីត្រ ទឹកស៊ីអ៊ីវ១កេស ថវិកាចំនួនមួយលានរៀល។ បានផ្តល់ជូនបុគ្គលិកចំនួន៧នាក់ ក្នុងម្នាក់ៗទទួលបានចំនួនដប់ម៉ឺនរៀល និងផ្តល់ជូនកុមារកំព្រាចំនួន២៧នាក់ ដោយក្នុងម្នាក់ៗ ទទួលបានកាបូបស្ពាយ(ធំ)១ សៀវភៅ១០ក្បាល ប៊ិក២ដើម ទឹកដោះគោ២កំប៉ុង ទឹកក្រូច និងទឹកផ្លែឈើ៣កំប៉ុង សាប៊ូ១ដុំ ច្រាសដុសធ្មេញ១ និងថ្នាំដុសធ្មេញ១ កន្សែងពោះគោ១ នំ៧កញ្ចប់តូច ស្បែកជើង១គូ និងថវិកាចំនួនពីរម៉ឺនរៀល។

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)





*គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភាជួបសំណេះសំណាល និងសួរសុខទុក្ខកុមារកំព្រា នៅមជ្ឈមណ្ឌលបុរីកុមារខេត្តកែប*

# គណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញឈ្វេងយល់អំពីវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន នៅខេត្តសៀមរាប



*ឯកឧត្តម គង់ សារាជ ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា*

ក្នុងអំឡុងពេល នៃចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី១០ និងទី១១ គណៈប្រតិភូគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា (គណៈកម្មការទី៩) ដឹកនាំដោយឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការ បានអញ្ជើញទស្សនកិច្ចឈ្វេងយល់អំពីការរៀបចំដំណើរការអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ នៅខេត្តសៀមរាប ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

ក្នុងឱកាសបំពេញទស្សនកិច្ចឈ្វេងយល់នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ លោក Jia Suo អនុប្រធានក្រុមហ៊ុន Yunna Aviation Industry Investment Group Co., Ltd និងលោកប្រធាននាយកដ្ឋានស្តង់ដារ និងសុវត្ថិភាពអាកាសយានដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បានអញ្ជើញទទួលស្វាគមន៍យ៉ាងកក់ក្តៅនូវវត្តមានរបស់គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា និងបានជម្រាបជូនអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ចេញនូវវិស័យអាទិភាពជាច្រើន ក្នុងនោះពាណិជ្ជកម្មតាមផ្លូវអាកាស ក៏ជាផ្នែកមួយដ៏សំខាន់ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។ អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ត្រូវបានវិនិយោគដោយ Angkor International Airport Investment (Cambodia) Co., Ltd (AIAI) ដែលជាសាខារបស់ក្រុមហ៊ុន Yunna Aviation Industry Investment Group Co., Ltd ។ សំណង់អាកាសយានដ្ឋាននេះ មានទីតាំងស្ថិតនៅភូមិក្រៀលពង ឃុំពពេល និងភូមិប្រវ៉ាល ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប លើផ្ទៃដី ១.៧០០ហិកតា ក្នុងនោះផ្ទៃដីសម្រាប់ធ្វើការសាងសង់អាកាសយានដ្ឋានមានទំហំ ៧០០ហិកតា និងផ្ទៃដីទំហំ ១.០០០ហិកតា សម្រាប់កសាងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មរណបឱ្យអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដែលអាចហៅថា "ទីក្រុងអាកាសយានដ្ឋាន Airport City" នាពេលខាងមុខ។ ផ្លូវថ្មីដែលទើបសាងសង់រួចរាល់នោះ ហៅថា "Special Airport highway" ដែលជាប្រភេទផ្លូវបេតុងកៅស៊ូ មិនមែនជាប្រភេទផ្លូវល្បឿនលឿន





*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយនឹងក្រុមហ៊ុន Yunna Aviation Industry Investment Group Co., Ltd*



ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ

ទេ តែជាប្រភេទផ្លូវកាត់ដែលតភ្ជាប់ពីផ្លូវជាតិលេខ៦ ទៅដល់អាកាសយានដ្ឋានមានប្រវែង២៤,៥គីឡូម៉ែត្រ។ អាកាសយានដ្ឋាននេះស្ថិតក្នុងកម្រិត4E មានផ្លូវរត់ (Runway) ប្រវែង៣.៦០០ម៉ែត្រ ទទឹង៤៥ម៉ែត្រ មាន៣៨ចំណតយន្តហោះ និងមានក្រឡាផ្ទៃស្ថានីយអ្នកដំណើរជាង៨ម៉ឺនម៉ែត្រក្រឡា ដែលអាចទទួលអ្នកដំណើរជាប្រចាំឆ្នាំប្រមាណ៧លាននាក់។ សំណង់នេះ ត្រូវបានធ្វើឡើងក្នុងទម្រង់វិនិយោគ “សាងសង់ធ្វើអាជីវកម្មផ្ទេរ” (BOT) ដែលមានរយៈពេល៥៥ឆ្នាំ ក្នុងនោះ៥ឆ្នាំសម្រាប់ការសាងសង់ និង៥០ឆ្នាំសម្រាប់ប្រតិបត្តិការអាជីវកម្ម។ ផ្នែកជំនាញពាក់ព័ន្ធបានសម្របសម្រួលជាមួយនឹងក្រុមហ៊ុន (AIAI) ដើម្បីទទួលយកបុគ្គលិកដែលកំពុងបម្រើការនៅអាកាសយានដ្ឋានបច្ចុប្បន្នទាំងអស់ ទៅធ្វើការនៅអាកាសយានដ្ឋានថ្មីក្រោមគោលការណ៍ស្ម័គ្រចិត្ត។

ក្នុងឱកាសនោះ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនរបស់វិស័យអាកាសចរណ៍ស៊ីវិលជាមួយនឹងសមិទ្ធផលថ្មីៗជាច្រើន ពិសេសអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដែលនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដូចជា៖ ១-អាកាសយានដ្ឋានថ្មីនេះស្ថិតនៅតំបន់មួយដែលមិនមានផលប៉ះពាល់ផ្នែកបរិស្ថាន សង្គម និងវប្បធម៌។ ២-មានសមត្ថភាពគ្រប់គ្រាន់ទទួលយន្តហោះប្រភេទធំៗគ្រប់ប្រភេទអាចចុះចតបាន។ វិស័យអាកាសចរណ៍ គឺជាចក្ខុវិស័យដែលជាគោលដៅយុទ្ធសាស្ត្រ នៃការអភិវឌ្ឍប្រកបដោយចីរភាព ជំរុញទាក់ទាញវិនិយោគិន ពាណិជ្ជកម្ម ទំនិញ សេវាកម្មទេសចរណ៍ លើកកម្ពស់ការពង្រឹងសុវត្ថិភាព សន្តិសុខអាកាសចរណ៍ស៊ីវិល ដែលជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល នឹងរំពឹងថា នៅឆ្នាំ២០២៤ ឬដើមឆ្នាំ២០២៥ អាកាសយានដ្ឋានថ្មីនេះបានត្រៀមខ្លួនរួចរាល់ និងអាចប្រកួតប្រជែងជាមួយនឹងប្រទេសជិតខាងបាន។ សមិទ្ធផលគួរជាទីមោទនៈនេះ ក៏បានឆ្លុះបញ្ចាំងដល់ទំនាក់ទំនងល្អជាផ្លែផ្កានៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន មិនអាចកាត់ថ្លៃបាន។ អាកាសយានដ្ឋានថ្មីនេះ នឹងជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ភាគខាងជើង ពិសេសផលប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះដែលត្រូវបានសម្តេចតេជោ **ហ៊ុន សែន** បានប្រសិទ្ធនាមថា “ជាតារាវៈនាទិសឧត្តរ”។

ក្រៅពីបំពេញទស្សនកិច្ចនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ក៏បានអញ្ជើញទស្សនកិច្ចតំបន់ឧទ្យានអង្គរ រមណីយដ្ឋានបារាយទឹកថ្លា ស្ថិតនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាបផងដែរ៕

(អត្ថបទ និងរូបភាព៖ វង់ សុជាតិ)





គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ទស្សនកិច្ចឈ្វេងយល់នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១១ នៅវត្តចំនួន៥ ក្នុងឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង





*ក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញសូត្រមន្តកាន់បិណ្ឌវេនទី១១*

នាព្រឹកថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភា បានអញ្ជើញនាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១១ នៅវត្តចំនួន៥ រួមមាន៖ វត្តស្វាយទាប វត្តពោធិ៍សត្ថារាម (ហៅវត្តពានា) វត្តឧត្តមពោធិ៍និស្ស័យ (ហៅវត្តក្បាលបឹង) វត្តសេរីមង្គលអំពិលក្រៅ វត្តទួលមានជ័យ (ហៅវត្តទួលជ្រៃ) ស្ថិតក្នុងឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។

នាឱកាសដ៏ថ្លៃថ្លានោះ ក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញថ្វាយនូវគ្រឿងសក្ការបូជា ទៀន ធូប ផ្កាភ្ញី និងប្រារព្ធកិច្ចបទនមស្ការព្រះរតនត្រ័យ សមាទាននិច្ចសីល និមន្តព្រះសង្ឃសូត្រព្រះធម៌ស្វាធ្យាយ ចម្រើនព្រះបរិត្ត និងពុទ្ធជ័យមង្គល ព្រមទាំងនាំយកចង្ហាន់ ទេយ្យទាន គ្រឿងបរិក្ខារ រាប់បាត្រ វេរប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យ ដែលកើតពីសទ្ធាជ្រះថ្លាទាំងនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធញាតកាទាំងប្រាំពីរសន្តាន ជាពិសេសជូនចំពោះដួងវិញ្ញាណក្ខន្ធអតីតថ្នាក់ដឹកនាំ អតីតសមាជិក សមាជិកាព្រឹទ្ធសភា ឥស្សរជន និងយុទ្ធជន ដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ សូមឱ្យទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

ទេយ្យទាន គ្រឿងបរិក្ខារផ្សេងៗ ដែលក្រុមសមាជិកាព្រឹទ្ធសភាបាននាំមកប្រគេនដល់ព្រះសង្ឃទាំង៥វត្ត នាពេលនោះ រួមមាន៖ អង្ករ មី ទឹកបរិសុទ្ធ ទឹកក្រូច ទឹកផ្លែឈើ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខ ផ្លែឈើ នំអន្សមខ្មែរ និងទេយ្យទានផ្សេងៗទៀត ព្រមទាំង ប្រគេន បច្ច័យសម្រាប់កសាងវត្តទាំង៥ ក្នុងមួយវត្តៗចំនួន១លាន៥សែនរៀល ផងដែរ៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)





*ក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១១*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ ដើម្បីពិនិត្យលើ៖

១-របាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣

២-របាយការណ៍ចន្លោះសម័យប្រជុំលើកទី១០ របស់គណៈកម្មការ

៣-អំពីថវិកា។



-កិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៧ (Inter-Parliamentary Union 147) នៅទីក្រុង Luanda ប្រទេស Angola នៅសាលប្រជុំពិសេស (VIP3) វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ ដើម្បីពិភាក្សាលើរបៀបវារៈរួមមាន៖

១-មតិរបស់ឯកឧត្តមប្រធានគណៈប្រតិភូ

២-របាយការណ៍ស្តីពី ដំណើរការរៀបចំមហាសន្និបាត IPU 147 រាយការណ៍ដោយ ឯកឧត្តម អគ្គនាយក-ពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា មន្ត្រីព្រឹទ្ធសភា និងរដ្ឋសភា។

៣-កន្លែងទំនេរ នៃប្រធាន IPU និងកន្លែងទំនេរផ្សេងៗទៀត

៤-គណៈកម្មការសិទ្ធិមនុស្សរបស់សមាជិកសភា IPU

៥-រៀបចំបញ្ជីឈ្មោះសមាជិក សមាជិកា និងមន្ត្រីទទួលភារកិច្ចនៅក្នុងគណៈកម្មការនីមួយៗ

៦-មន្ត្រីរាយការណ៍អំពី ការចាក់វ៉ាក់សាំង ការធ្វើដំណើរការស្នាក់នៅ និងការហូបចុក

៧-ផ្សេងៗ។



-កិច្ចប្រជុំត្រៀមចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៧ (IPU 147) នៅទីក្រុង Luanda ប្រទេស Angola ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នាពេលខាងមុខ ព្រមទាំងស្តាប់បទបង្ហាញស្តីពីការគ្រប់គ្រង និងព្យាបាលជំងឺគ្រុនចាញ់ស្រាល និងធ្វើតេស្តឈាមរកមេរោគគ្រុនចាញ់ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

-កិច្ចប្រជុំពិភាក្សាការងារជាមួយនឹងតំណាងក្រសួងការ-



បរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ និងតំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីត្រៀមចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភាលើកទី ១៤៧ (IPU 147) នៅទីក្រុង Luanda ប្រទេស Angola ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នាពេលខាងមុខ នៅសាលខាងជើងព្រឹទ្ធសភា នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។



-កិច្ចប្រជុំលើកទី៣ ដើម្បីត្រៀមលក្ខណៈមុនអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៧ (IPU-147) ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នាពេលខាងមុខ នៅសាលប្រជុំពិសេស (VIP3) វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ខេដ្ឋ** ប្រធានគណៈ-កម្មការទី២ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី



ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ។



-ចូលរួមមហាសន្និបាតប្រចាំឆ្នាំ នៃបណ្តាញក្រុមសីលធម៌សមាជិកហ្វ្រង់កូហ្វូន តាមប្រព័ន្ធនិម្មិត ផ្សាយចេញពីខេត្តកេបិច (Quebec) ប្រទេសកាណាដា ដែលប្រព្រឹត្តទៅរយៈ-ពេលពីរថ្ងៃ គឺថ្ងៃទី១២ និងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នារាត្រីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត

**ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអនុញ្ញាតឱ្យបណ្ឌិត **យ៉េន យ៉ាត** ប្រធានដឹកនាំគម្រោង និងជាអ្នកជំនាញការផ្នែកសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន DCX Co LTD ដែលជាដៃគូសហប្រតិបត្តិការជាមួយនឹងក្រសួងបរិស្ថាន ចូលជួបពិភាក្សាការងារ ដើម្បីសិក្សាឈ្វេងយល់អំពីទស្សនសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅកម្ពុជា ចំណេះដឹង ឥរិយាបថ និងការអនុវត្ត។ ជាទីបញ្ចប់នៃជំនួបពិភាក្សាតំណាងក្រសួងបរិស្ថាន បានស្នើសុំដឹកនាំគណៈប្រតិភូមួយក្រុម ដើម្បីចុះទៅពិនិត្យសិក្សាដោយផ្ទាល់ នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ និងតំបន់អភិវឌ្ឍន៍កសិកម្ម កសិ-ឧស្សាហកម្ម ចម្ការដូងប្រេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំការងារនៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យលើរបៀបវារៈ



ដូចខាងក្រោម៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងាររបស់គណៈកម្មការប្រចាំខែកញ្ញា និងរបាយការណ៍នព្វមាស ឆ្នាំ២០២៣

២-ការពិនិត្យរបាយការណ៍សកម្មភាពការងាររបស់គណៈកម្មការប្រចាំនីតិកាលទី៤ ចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២៣

៣-ការបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែកញ្ញា និងរបាយការណ៍នព្វមាស ឆ្នាំ២០២៣

៤-បញ្ហាផ្សេងៗ។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ហើយគណៈកម្មការយល់ឃើញថា សេចក្តីព្រាងច្បាប់ខាងលើនេះអាចលើកយកមកពិនិត្យសិក្សា ហើយឱ្យយោបល់បាន នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-កិច្ចប្រជុំអន្តរគណៈកម្មការជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នៅសាលប្រជុំ



ពិសេសព្រឹទ្ធសភា នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

-កិច្ចប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សា ហើយឱ្យយោបល់ជាលើកចុងក្រោយ លើសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាក្រុមទី៥ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ដើម្បីពិនិត្យពិភាក្សាលើ៖

១-ត្រៀមឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និង

២-បញ្ហាផ្សេងៗ។



❈នាព្រឹកថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារប្រចាំខែតុលា និងលើកទិសដៅការងារបន្ត



នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។




❈នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញផ្ដល់កិត្តិយសធ្វើបទសម្ភាសន៍ជាមួយនឹងលោក **ជួប សុខចំរើន** នាយកប្រតិបត្តិអង្គការខាណា (KHANA) តាមប្រព័ន្ធនិម្មិត (Zoom) ស្ដីពី សហគមន៍ សិទ្ធិ និងយេនឌ័រ សម្រាប់ការឆ្លើយតបនឹងជំងឺរបេង នៅសាលប្រជុំគណៈ-កម្មការទី៨ព្រឹទ្ធសភា ក្រោមប្រធានបទ៖

១-ក្រុមប្រជាជនសំខាន់ៗជាគោលដៅ នៃជំងឺរបេង

២-បរិយាកាសផ្លូវច្បាប់ ការប្រមាថមាក់ងាយ និងការរើសអើង ភាពលាក់ការណ៍សម្ងាត់ ការដាក់ទោស-ទណ្ឌ ការទទួលបានជំនួយផ្លូវច្បាប់ ការទទួលបានសេវាគាំពារសង្គម

៣-បទពិសោធន៍ នៃការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជំងឺកូវីដ-១៩ ជាឱកាសយុទ្ធសាស្ត្រ ដើម្បីបញ្ចប់ជំងឺរបេង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញនាំយកចង្ហាន់ ទេយ្យវត្ថុ និងបច្ច័យមួយចំនួនប្រគេនដល់ព្រះសង្ឃគង់នៅវត្តរកាកណ្តាល ព្រមទាំងជួបសំណេះសំណាលជាមួយនឹងយាយជី តាជី និងឧបត្ថម្ភថវិកាមួយចំនួន នៅក្រុងក្រចេះ ខេត្តក្រចេះ។



❋នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចុះសួរសុខទុក្ខលោក **គ្រី ម៉េងហុង** អាយុ៥៧ឆ្នាំ កំពុងសម្រាកព្យាបាលជំងឺនៅផ្ទះ (ជំងឺស្ទះសរសៃឈាមពិការដៃ និងជើង) នៅសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និលោក **ទេព ឡុងរចនា** អាយុ ៦២ឆ្នាំ កំពុងសម្រាកព្យាបាលជំងឺនៅផ្ទះ (ជំងឺវះកាត់បេះដូងនៅប្រទេសវៀតណាម) នៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

❋ឯកឧត្តមបណ្ឌិត**ម៉ុង ឫទ្ធី**ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិ-ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន ទំនប់ទឹក និងរំដោះជំនន់ទឹកភ្លៀងជូនប្រជាពលរដ្ឋ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារគ្រឿងចក្រសាងសង់ផ្លូវមួយខ្សែប្រវែង៥គីឡូម៉ែត្របន្ថែមទៀត នៅតំបន់ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងពិនិត្យមើលទំនប់ទឹក ហេដ្ឋារចនាសម្ព័ន្ធនានា និងចុះពិនិត្យក្រុមការងារសាងសង់ផ្លូវឡូរីប្រវែង៥.០០០ម៉ែត្រ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកសម្រាកកម្សាន្តនៅតំបន់ទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន ព្រមទាំងចុះសួរសុខទុក្ខកម្មករ និងចុះដឹកនាំក្រុមការងារគ្រឿងចក្ររៀបចំទីតាំងដីទំហំ១០ហិកតា សម្រាប់ដាំបន្លែសរីរាង្គ និងចិញ្ចឹមត្រីទឹកសាប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខយុវជនរងគ្រោះដោយសារការសេពគ្រឿងញៀន នៅមជ្ឈមណ្ឌលជាតិ-ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសមាគម (ភូមិឫទ្ធី២) ព្រមទាំងនាំយកអង្ករ មី ទឹកត្រី ជាច្រើនឧបត្ថម្ភដល់ពួកគាត់ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យរថយន្តបណ្តាញអគ្គិសនីសម្រាប់ផ្គត់ផ្គង់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋា-

រចនាសម្ព័ន្ធ ផ្លូវ ទឹក ភ្លើង នៅលើផ្ទៃដី១៧២ហិកតា ដើម្បីត្រៀមបម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលអញ្ជើញមកទស្សនាសួនសត្វ និងសម្រាកកម្សាន្តនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងអញ្ជើញទទួលឯកឧត្តម **ឡៅ វិចិត្រ** នាំយកសត្វស្វាព្រាមចំនួន២ក្បាល និងសត្វពង្រូលចំនួន១ក្បាល យកមកថែរក្សាទុកនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣។

- ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងប្រជាពលរដ្ឋចំនួន៣០៩នាក់ ព្រមទាំងឧបត្ថម្ភសាច់ជ្រូកជូនពួកគាត់ ក្នុងម្នាក់ៗចំនួន២គីឡូក្រាម នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងណែនាំពួកគាត់អំពីការថែទាំដី ដើម្បីដាំដំណាំស្រូវទទួលបានផលល្អ ព្រមទាំងសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលអញ្ជើញមកសម្រាកកម្សាន្ត ទស្សនាសួនសត្វ ព្រះវិហារសហចេតិយ និងណែនាំពួកគាត់អំពីការបណ្ដុះថែទាំកូនដើមឈើផងដែរ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

-នាំយកចង្ហាន់ និងទេយ្យទានប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា នៅវត្តព្រៃដំបង ភូមិបន្លាស្អិត ឃុំរលាំងចក ភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាសួនសត្វ ព្រមទាំងសិក្សាឈ្វេងយល់នៅតំបន់កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែន-ជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣។

-ដឹកនាំប្រជាពលរដ្ឋចុះចំនួន៤០នាក់ ចុះពិនិត្យ និងសិក្សាឈ្វេងយល់រោងចក្រផលិតចំណីសត្វ រោងចក្រកែច្នៃផ្លែដូងប្រេងស្រស់ នៅតំបន់អភិវឌ្ឍន៍ឧកញ៉ាម៉ុង កែវផុស នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣។

❋នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា អញ្ជើញជួបសំណេះ-សំណាលជាមួយនឹងប្រជាពលរដ្ឋ នៅស្រុកព្រះស្ដេច ខេត្តព្រៃវែង។



❋នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិ-កោសលបណ្ឌិត **ទី ម៉ារ៉ាសុី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ប្រធានមន្ទីរពេទ្យបង្អែកស្រុក និងប្រធានមណ្ឌលសុខភាព ទូទាំងស្រុកពញាឮ ខេត្តកណ្ដាល ព្រមទាំងនាំយកឃីតសម្ភារៈរក្សាសុខភាពចំនួន១៦០ឃីត ជាអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងថវិកាមួយចំនួនជូនការិយាល័យមន្ទីរពេទ្យ មណ្ឌលសុខភាព ក្រុមការងារ និងចូលរួមកម្មវិធីបុណ្យដាក់បិណ្ឌនៅវត្តព្រែកប្រាំង និងបវារ-ណាប្រគេន សម្ដេចព្រះឧត្តមបញ្ញា **ដួង ផង់** ព្រះគ្រូចៅអធិការវត្ត រួមមាន៖ ចង្ហាន់ ភេសជ្ជៈ នំចំណី អង្ករ និងថវិកាមួយចំនួនបវារណាប្រគេនព្រះសង្ឃចំនួន៥វត្តផ្សេងទៀតក្នុងស្រុកពញាឮ ខេត្តកណ្ដាល។

❋ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ នៅឃុំដាស្រុកមេមត់ ខេត្តត្បូងឃ្មុំ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពីតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្ដល់សេវាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣។



❈នាថ្ងៃទី៣ និងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌីមហ៊ុយ** ប្រធានគណៈ-កម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់កំបូល ខណ្ឌកំបូល និងក្រុមប្រឹក្សាសង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១ នៅវត្តបទុមវតី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តវាលស្បូវ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានី-ភ្នំពេញ នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិក្បាលបឹង ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាថ្ងៃទី៨ និងថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចតេជោ **ហ៊ុន សែន** ចុះពិនិត្យ និងព្យាបាលជំងឺភ្នែកជូនប្រជាពលរដ្ឋឃុំគោកត្រប់ បានចំនួន២១៥នាក់ និងវះកាត់ភ្នែកចំនួន ១៩នាក់ ដោយ



ឥតគិតថ្លៃ នៅឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១ ព្រមទាំងនាំយកថវិកាមួយចំនួនរបស់គណៈកម្មការទី១០ ព្រឹទ្ធសភាចូលបុណ្យ នៅវត្តបទុមវត្តី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានី-ភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៨ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តកោកកាក ព្រមទាំងនាំយកអំណោយចែកជូនដល់តាជី និងយាយជី ដោយក្នុងម្នាក់ៗទទួលបាន៖ កន្សែងពោះគោ១ និងថវិកាមួយចំនួន នៅឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាព្រឹកថ្ងៃ៧ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តក្អួន ព្រមទាំងនាំយកអំណោយចែកជូនដល់តាជី និងយាយជី ដោយក្នុងម្នាក់ៗទទួលបាន៖ កន្សែងពោះគោ១ និងថវិកាមួយចំនួន នៅឃុំត្រពាំងវែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល នាព្រឹកថ្ងៃ៨ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១៤ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តកំបូល ព្រមទាំងនាំយកអំណោយចែកជូនដល់តាជី និងយាយជី ដោយក្នុងម្នាក់ៗទទួលបាន៖ កន្សែង-ពោះគោ១ និងថវិកាមួយចំនួន នៅសង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ នាព្រឹកថ្ងៃ១៣ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១៤ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តពេជ្រនិល ព្រមទាំងនាំយកអំណោយចែកជូនដល់តាជី និងយាយជី ដោយក្នុងម្នាក់ៗទទួលបាន៖ កន្សែង-ពោះគោ១ និងថវិកាមួយចំនួន នៅឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃ១៣ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ និងបាននាំយក

គ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តចង្ក្រានតាព្រហ្មស្ទឹងមានជ័យ និងនៅវត្តនន្ទមុន្នី ព្រមទាំងនាំយកអំណោយចែកជូនដល់តាជី និងយាយជី ដោយក្នុងម្នាក់ៗទទួលបាន៖ កន្សែងពោះគោ១ និងថវិកាមួយចំនួន នៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នាព្រឹកថ្ងៃ១៤ ខែតុលា ឆ្នាំ២០២៣។

❈នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញកាន់បិណ្ឌវេនទី១ និងប្រគេនបច្ច័យមួយចំនួនកសាង នៅវត្តពោធិ៍រាម ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

❈នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

❈នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំអំពី តួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្ដល់សេវាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅក្នុងស្រុកកោះកុង ខេត្តកោះកុង។

❈ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា៖



-នាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តត្រើយកោះ នៅក្រុងកំពត ខេត្តកំពត នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-នាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់ បិណ្ឌបាត និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១៣ នៅវត្តសុវណ្ណារ៉ាម ហៅវត្តទួលអង្គ នៅភូមិក្រាំងស្ដៅ ឃុំសឹង ស្រុកសំរោង ខេត្តតាកែវ នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ



២០២៣។



-នាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់ បិណ្ឌបាត្រ និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១៤ នៅវត្តចរិយាវង្ស ស្ថិតនៅសង្កាត់អូរក្រសារ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខលោកតា លោកយាយចាស់ជរា និងពិការភ្នែក នៅតាមគេហដ្ឋាន ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ និងថវិកាមួយចំនួន នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងបងប្អូនប្រជាពលរដ្ឋ ដើម្បីស្ដាប់យោបល់ឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣។



-ចូលរួមពិធីសូត្រមន្តកាន់បិណ្ឌវេនទី១ ទី៣ ទី៥ ទី១៥ ព្រមទាំងនាំយកចង្ហាន់ ទេយ្យទាន និងបច្ច័យប្រគេនដល់ព្រះសង្ឃសមាទានសីលអស់កាលត្រីមាសតាមពុទ្ធបញ្ញត្តនៃព្រះសម្មាសម្ពុទ្ធជាអម្ចាស់ នៅវត្តបុទុមវត្តី វត្តនាគវ័ន្ត វត្តពូនភ្នំ និងវត្តច័ន្ទបុរីវង្ស រាជធានីភ្នំពេញ នាថ្ងៃទី២៩ ខែកញ្ញា និងថ្ងៃទី២ ថ្ងៃទី៤ និងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣។



-ចូលរួមប្រជុំជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ដើម្បីវាយតម្លៃវឌ្ឍនភាពការងារខែតុលា និងទិសដៅបន្ត ព្រមទាំងប្រគល់ប័ណ្ណសម្គាល់គ្រួសារងាយរងហានិភ័យដែលបានធ្វើសម្ភាសន៍យ៉ាងជាក់លាក់តាមប្រព័ន្ធព័ត៌មានវិទ្យា និងសម្រេចអនុញ្ញាត ដោយក្រសួងផែនការ បានចំនួន២២គ្រួសារ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣។

❈នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញកាន់បិណ្ឌវេនទី៨ នៅវត្តព្រះពន្លា ព្រមទាំងចុះសួរសុខទុក្ខចាស់ជរាក្នុងភូមិព្រះពន្លា នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

❈ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធ និងចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោក **អ៊ុយ ឆារត្ន** និងចូលបច្ច័យចូលបុណ្យមួយចំនួន នៅភូមិសំណង់ សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមពិធីកាន់បិណ្ឌវេនទី១ និងបាននាំយកគ្រឿងឧបភោគ បរិភោគ ទេយ្យទាន និងបច្ច័យមួយចំនួនវេរប្រគេនព្រះសង្ឃគង់នៅវត្តនាគវ័ន្ត នៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំក្រុមការងារចុះជួយខេត្តកំពង់ស្ពឺ ស្ដីពី ការបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ អាណត្តិទី៧ និងលើកទិសដៅការងារនៅទីរួមខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-គោរពវិញ្ញាណក្ខន្ធ និងចូលរួមរំលែកទុក្ខជាមួយលោកឧត្តមសេនីយ៍ទោ **សម សាម្ផូន** ស្នងការនគរបាលខេត្តកំពង់ស្ពឺ ដែលឧបាសិកា **ឡួន ឆេង** ត្រូវជាម្ដាយបង្កើតបានទទួលមរណភាពដោយរោគាពាធ និងបានចូលបច្ច័យបុណ្យមួយចំនួន នៅខេត្តស្វាយរៀង នារសៀលថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលជាមួយនឹងមន្ត្រីរាជការចូលនិវត្តន៍ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់មន្ត្រីរាជការចូលនិវត្តន៍ និងអាហារសម្រន់ចំនួន១ប្រអប់ នៅមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយ និងថវិកាមួយចំនួនជូនលោកយាយ **ញឹក សៀង** អតីតគ្រូ-បង្រៀនចូលនិវត្តន៍ នៅក្រុងតាខ្មៅ ខេត្តកណ្ដាល នារសៀលថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌ និងបាននាំយកគ្រឿងឧបភោគបរិភោគទេយ្យទាន និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រៃពួច ដើម្បីឧទ្ទិសកុសលជូនដល់បុព្វការីជន និងញាតកាទាំងប្រាំពីរសន្តានដែលបានចែកឋានទៅកាន់លោកខាងមុខ នៅឃុំព្រៃពួច ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣។

❈នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

❈ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីមិទ្ទីញ និងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្ដីពី "ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ" និង "យើងរួមគ្នាការពារបរិស្ថានកម្ពុជា" រវាងក្រសួងបរិស្ថានជាមួយខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកណ្ដាល នៅក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្ដមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារពិសេស និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅទីរួមខេត្តស្វាយរៀង នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមបុណ្យសពប្អូនស្រីបង្កើតឯកឧត្ដម **ឯក ត្រឿន** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ក្នុងជន្មាយុ៧២ឆ្នាំ ដោយរោគាពាធ នៅភូមិជប់ព្រីង ឃុំថ្មី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣។

-រៀបចំពិធីកាន់បិណ្ឌវេនទី៥ នៅវត្តសន្តិភាព ព្រមទាំងនាំយកគ្រឿងបរិក្ខារ និងបច្ច័យមួយចំនួន នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តព្រះពន្លា ព្រមទាំងវេរទេយ្យទាន និងទេយ្យវត្ថុប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ដើម្បីឧទ្ទិសកុសលផលបុណ្យជូនចំពោះញាតកាទាំងប្រាំពីរសន្តាន នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យសពឧបាសិកា **រស់ ដា** ជន្មាយុ៧៦ឆ្នាំ ដោយរោគាពាធ ត្រូវជាបងប្អូនឯកឧត្ដម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា នៅភូមិស្វាយតានី ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១៤ នៅវត្តត្នោត (ហៅវត្តឯក) និងវត្តពោធិ៍ម្មម មានគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត និងនាំយកបច្ច័យមួយចំនួន ព្រមទាំងវេរទេយ្យទាន និងទេយ្យវត្ថុប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់ត្រីមាស ដើម្បីឧទ្ទិសកុសលផលបុណ្យជូនចំពោះញាតកាទាំងប្រាំពីរសន្តាន នៅឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សា ឃុំ ស្រុក ដើម្បីឈ្វេងយល់ពីការចុះឈ្មោះ ពិនិត្យឈ្មោះបោះឆ្នោតប្រជាពលរដ្ឋឆ្នាំ២០២៣ និងការចុះឈ្មោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលទី៥ នាពេលខាងមុខនេះ នៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

❁ឯកឧត្ដម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង១៣ ស្រុកមង្គលបូរី ក្រុមប្រឹក្សាសង្កាត់ទាំង៧ ក្រុងសិរីសោភ័ណ ក្រុមប្រឹក្សាឃុំទាំង៨ ស្រុកស្វាយចេក ក្រុមប្រឹក្សាទាំង៩ ស្រុកអូរជ្រៅ ក្រុមប្រឹក្សាឃុំទាំង៩ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដើម្បីជម្រាបជូនអំពីដំណើរការ នៃការបង្កើតស្ថាប័នព្រឹទ្ធសភា ចាប់ពីនីតិកាលទី១ ដល់នីតិកាលទី៤ និងអំពីការត្រៀមលក្ខណៈចូលរួមបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ ខាងមុខ ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង៦ ស្រុកថ្មពួក ក្រុមប្រឹក្សាទាំង៥ ក្រុងប៉ោយប៉ែត ក្រុមប្រឹក្សាឃុំទាំង៦ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីជម្រាបជូនអំពីដំណើរការ នៃការបង្កើតស្ថាប័នព្រឹទ្ធសភា ចាប់ពីនីតិកាលទី១ ដល់នីតិកាលទី៤ និងអំពីការត្រៀមលក្ខណៈចូលរួមបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា នីតិកាលទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤ ខាងមុខនេះ។



-ចូលរួមពិធីកាន់វេនបិណ្ឌទី៩ និងទី១១ ព្រមទាំងនាំយកនូវភេសជ្ជៈ ចង្ហាន់ ទេយ្យវត្ថុ និងបច្ច័យប្រគេនដល់ព្រះសង្ឃដែលបានចូលនៅរក្សាសីលអស់កាលត្រីមាស តាមពុទ្ធានុញ្ញាត នៅវត្តសុវណ្ណគីរីភ្នំជញ្ជាំង ឃុំជប់វារី និងវត្តពោធិ៍កែវ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៨ និងថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីប្រគល់ប័ណ្ណសរសើរដល់សិស្សានុសិស្សទទួលជ័យលាភីលទ្ធផលសិក្សាដំណាច់ឆ្នាំ២០២២-



២០២៣ នៅសាលាសេហ្សហេរ៉ិ ក្នុងភូមិកូនដំរី សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ និងថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២៣។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តកំសាន្ត ភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៦ នៅវត្តអង្គពោធិ៍ញាណ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-កាន់បិណ្ឌវេនទី៥ នៅវត្តព្រៃជ្រាំង ឃុំពានរោង ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខលោក **នួន ថូ** ប្រធានក្រុមប្រឹក្សាស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១០ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃ



គង់នៅវត្តសំបូរណ៍ ហៅវត្តវិហារសសរមួយរយ នៅស្រុកសំបូរណ៍ ខេត្តក្រចេះ នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១៣ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តអម្ពិលារាមហៅវត្តអំពិលតាពក ឃុំអំពិលតាពក និងវត្តព្រះធាតុបាស្រី នៅឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យពុទ្ធាភិសេកព្រះពុទ្ធបដិមានៅព្រះវិហារវត្តអម្ពវ័ន ក្រោមអធិបតីភាពឯកឧត្ដម **ជា សុផារ៉ា** ឧត្ដមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាល្ងាចថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តហ្លួងព្រះស្ដេចកនហៅវត្តព្រៃអង្គរក្នុង នៅភូមិព្រៃអង្គរក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីប្រណាំងទូកងដែលរៀបចំឡើងដោយរដ្ឋបាលខេត្តត្បូងឃ្មុំ ដើម្បីអបអរសាទរពិធីបុណ្យភ្ជុំបិណ្ឌ នៅអាងទឹកសោភណ្ឌត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣។

❈នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ឯកឧត្ដម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញដាក់បិណ្ឌវេនទី១២ និងបាននាំយកគ្រឿងឧបភោគ បរិភោគ សម្ភារៈបរិក្ខារមួយចំនួន ព្រមទាំងបច្ច័យទៅប្រគេនព្រះសង្ឃទាំងប្រាំពីរវត្ត នៅភូមិរកាខ្សុក ឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង។

❈ឯកឧត្ដម **ញ៉ែវ សុខ** សមាជិកគណៈកម្មការទី២ ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកទេយ្យវត្ថុ បរិក្ខារ អំពូលភ្លើង បច្ច័យ និងចង្ហាន់បិណ្ឌបាត្រ ទៅប្រគេនព្រះសង្ឃ និងចូលរួមពិធីបុណ្យ-

កាន់បិណ្ឌទី៥ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អាចារ្យចាស់ៗ និងចាប់មគ្គផលវេនកាន់បិណ្ឌបន្តបន្ទាប់ចំនួន៣វេន នៅវត្តនទីសេដ្ឋា ឃុំស្យា ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

-នាំយកគ្រឿងឧបភោគ បរិភោគ បច្ច័យកសាង បច្ច័យបង្សុកូល និងចង្ហាន់បិណ្ឌបាត្រ ចូលរួមជាមួយពុទ្ធបរិស័ទក្នុងពិធីកាន់បិណ្ឌវេនទី៦ និងប្រគេនព្រះសង្ឃ ព្រមទាំងចូលរួមថវិកាសម្រាប់បិណ្ឌខាងមុខចំនួន២វេន និងឧបត្ថម្ភថវិកាមួយចំនួនដល់គណៈកម្មការវត្ត យាយ តា នៅវត្តពោធិ៍សុវណ្ណរង្សី ឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣។

-នាំយកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ បច្ច័យ៤ និងបច្ច័យបង្សុកូលទៅចូលរួមកាន់បិណ្ឌវេនទី៨ និងប្រគេនព្រះពោធិវង្សាវិមលព្រះមេគណខេត្ត និងព្រះសង្ឃគង់នៅវត្តកែវវិជ័យ ក្នុងស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣។

-នាំយកនូវទេយ្យវត្ថុ គ្រឿងឧបភោគ បរិភោគ និងថវិកា បច្ច័យបួន បច្ច័យកសាងប្រគេនព្រះសង្ឃរួចរាប់បាត្រវេរចង្ហាន់បិណ្ឌបាត្រប្រគេនព្រះសង្ឃ នៅវត្តភ្នំលាំងត្រាច ឃុំស្វាយ-ស ស្រុកក្រគរ ខេត្តពោធិ៍សាត់ ព្រមទាំងចុះពិនិត្យមើលវឌ្ឍនភាព នៃការអភិវឌ្ឍរមណីយដ្ឋានទឹកធ្លាក់ច្រកល្មៀងដែលជារមណីយដ្ឋានកំពុងមានការនិយមចូលចិត្ត នៃភ្ញៀវទេសចរណ៍ក្នុងស្រុក នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្តម**ច្រឹង គឹមស្រ៊ាន**សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានិត** អនុប្រធានទី១ ក្រុមការងារថ្នាក់កណ្ដាលចុះមូលដ្ឋានខេត្តកំពង់ចាម នៅសាលប្រជុំស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមពិធីកាន់បិណ្ឌវេនទី៦ និងនាំយកទេយ្យវត្ថុបរិក្ខារ បច្ច័យ ចង្ហាន់ ប្រគេនព្រះសង្ឃ នៅវត្តសុស្សនារាម សង្កាត់ជ្រោយថ្ម ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីរំលែកមរណទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងពិសាអាហារសាមគ្គីជាមួយនឹងពួកគាត់ នៅភូមិត្រពាំងធំ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ ខេត្តកំពត នារសៀលថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅស្រុកអង្គរជុំ ខេត្តសៀមរាប។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំព្រៃគុយ ព្រមទាំងឧបត្ថម្ភក្រមាចំនួន៥០ក្រមា និងថវិកាមួយចំនួនដល់លោកប្រធានក្រុមប្រឹក្សាឃុំ នៅសាលាឃុំព្រៃគុយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្ដិ៍ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិសរុបចំនួន៥៤នាក់ ព្រមទាំងឧបត្ថម្ភក្រមាចំនួន៥៤ក្រមា និងថវិកាមួយចំនួនដល់លោកប្រធានក្រុមប្រឹក្សាឃុំនៅសាលាឃុំកំពង់ស្វាយស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

-កាន់បិណ្ឌវេនទី១ នៅវត្តឥន្ទប្បត្តបុរី (ហៅវត្តអង្គរតូចខាងត្បូង) ដើម្បីឧទ្ទិសកុសលជូនដល់បុព្វការីជន ជីដូនជីតាញាតកាទាំង៧សន្តាន ដែលលោកបានចែកឋានទៅកាន់លោកខាងមុខ និងបានប្រគេនបច្ច័យដល់ព្រះគ្រូចៅអធិការវត្តមួយចំនួនសម្រាប់ទុកកសាង ព្រមទាំងចែកអំណោយជូនលោកយាយ លោកតាចំនួន១៥០នាក់ ដោយម្នាក់ៗទទួលបាន៖ អង្ករ២៥គីឡូក្រាម មី១កេស ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ សារុង១ និងថវិកាមួយចំនួន នៅវត្តឥន្ទប្បត្តបុរី (ហៅវត្តអង្គរតូចខាងត្បូង) ឃុំក្រវ៉ាន់ ស្រុកអង្គរធំ ខេត្តសៀមរាប នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣។

-កាន់បិណ្ឌវេនទី៥ និងប្រគេនចង្ហាន់ បច្ច័យគ្រប់ព្រះអង្គ និងបច្ច័យសម្រាប់ទុកកសាងមួយចំនួននៅវត្តក្តីចារ្យ៍ ភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។



-កាន់បិណ្ឌវេនទី៦ និងប្រគេនចង្ហាន់បច្ច័យគ្រប់ព្រះអង្គ និងបច្ច័យសម្រាប់ទុកកសាងមួយចំនួន នៅវត្តកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមប្រារព្ធពិធីរាប់បាត្រ បង្សុកូល និងវេរប្រគេនបច្ច័យព្រះសង្ឃក្នុងឱកាសវេនកាន់បិណ្ឌវេនទី៨ នៅវត្តឥន្ទ្រីយ៍សំវរៈ(ហៅវត្តកំពង់ធំ) ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-នាំយកបច្ច័យ ទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងចង្ហាន់បិណ្ឌបាតប្រគេនព្រះគ្រូចៅអធិការវត្ត ចំនួន៣វត្តគឺ៖





វត្តសែនសិរី វត្តឥន្ទ្រីយ៍សំវរៈ និងវត្តចាន់មុលី នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅវត្តព្រះទន្លេ ព្រមទាំងវេរទេយ្យទាន និងទេយ្យវត្ថុប្រគេនព្រះសង្ឃគង់ចាំព្រះវិស្សាក្នុងវត្តព្រះទន្លេ ដើម្បីឧទ្ទិសកុសលផលបុណ្យជូនចំពោះញាតកាទាំងប្រាំពីរសន្តាន នៅសង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី១០ នៅវត្តមុនីប្រសិទ្ធិវង្ស នៅសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលអាជ្ញាធរភូមិអូររាំងខេន ដើម្បីឈ្វេងយល់អំពី ស្ថានភាពភូមិឃុំ សង្កាត់មានសុវត្ថិភាព ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន កាត់សម្លៀកបំពាក់សម្រាប់ប្រជាការពារភូមិ និងចែកជូនសៀវភៅស្វែងយល់អំពីហិង្សាក្នុងគ្រួសារ នៅឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រធានភូមិកណ្តាលដែលមានជំងឺត្រូវកាត់ជើង ត្រូវពិការជើងទាំងសងខាង នៅឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង នារសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៦

ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋនៅភូមិវែង ឃុំសឹង្គ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំអំពី តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្ដល់សេវាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន នៅស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ យុវជន ដើម្បីត្រួតពិនិត្យការងារខ្វះខាតកន្លងមក រកគន្លឹះដោះស្រាយ និងកែលម្អបានល្អប្រសើរ ព្រមទាំងនាំយកអំណោយ រួមមាន៖ អង្ករ ទឹកស៊ីអ៊ីវ ទឹកត្រី មី ប៊ីចេង អំបិល និងថវិកាមួយចំនួន ទៅជូនដល់ប្រជាពលរដ្ឋស្ត្រីមេម៉ាយមានកូនតូចៗ៤នាក់ ដែលកំពុងជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ និងធ្វើអំណោយដីបន្ថែមសម្រាប់សាងសង់ផ្ទះ និងបង្កបង្កើនផលចិញ្ចឹមជីវិត នៅឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងសមាជិក សមាជិកាក្រុមប្រឹក្សាស្រុក ឃុំ ប្រធានភូមិ ព្រមទាំងជូនលិខិតថ្លែងអំណរគុណ និងប័ណ្ណសរសើរ សមាជិកដែលមានស្នាដៃល្អ និងឧបត្ថម្ភអាហារសាមគ្គីនៅឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីកាន់បិណ្ឌវេនទី១ ទី៥ ទី៩ ទី១០ ទី១១ និងទី១៣ ព្រមទាំងនាំយកចង្ហាន់ ទេយ្យវត្ថុមួយចំនួនរួមមាន ៖ អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ ប៊ីចេង ទឹកបរិសុទ្ធ និងបច្ច័យប្រគេន



ដល់ព្រះសង្ឃដែលបានចូលនៅរក្សាសីលអស់កាលត្រីមាស តាមពុទ្ធានុញ្ញាត នៅវត្តបទុមវត្តី រាជធានីភ្នំពេញ វត្តប្រាសាទឥន្ទ្រា វត្តនគរភាស ឃុំនគរភាស ស្រុកពួក និងវត្តព្រៃដង្ហើម ឃុំកែវពណ៌ ខេត្តសៀមរាប វត្តបូរីប្រាសាទជ័យ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៩ ខែកញ្ញា និងថ្ងៃទី៤ ថ្ងៃទី៧ ដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីកាន់បិណ្ឌ វេន ទី៦ ទី៨ និងវេនទី១៤ ព្រមទាំងនាំយកភេសជ្ជៈ ចង្ហាន់ ទេយ្យវត្ថុ និងបច្ច័យប្រគេនដល់ព្រះសង្ឃ ដែលបានចូលនៅរក្សាសីលអស់កាលត្រីមាស តាមពុទ្ធានុញ្ញាត នៅវត្តបល្ល័ង្គ ឃុំពង្រ ស្រុករលាប្អៀរ វត្តពោធិ៍សត្ថារាម ឃុំកំពង់ហៅ ស្រុកកំពង់លែង វត្តខ្សាម សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង និងវត្តធម្មវ័ន្ត ឃុំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៥ ថ្ងៃទី៧ និងថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការស្មៀន ប៉ុស្តិ៍រដ្ឋបាលឃុំ ប្រធានភូមិ ចំណុះឃុំព្រៃគ្រី និងឃុំកំពង់អុស ដើម្បីឈ្វេងយល់ពីសភាពការណ៍ទូទៅរបស់ឃុំ ផែនការ



បន្ត និងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកចង្ហាន់ និងទេយ្យទាន រួមមាន ៖ មី ទឹកក្រូច ទឹកបរិសុទ្ធ បច្ច័យ ទៅប្រគេនព្រះសង្ឃគង់នៅវត្តគគីជុំភ្នំខ្វាវ នៅភូមិភ្នំលាវ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

-គោរពវិញ្ញាណក្ខន្ធសពឧបាសិកា **អាន គឹមសាយ** ត្រូវជាបងស្រីបង្កើតឯកឧត្តម **អាន ហេ** អតីតអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកែប បច្ចុប្បន្នទីប្រឹក្សាសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋានសព ភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣។



-នាំយកចង្ហាន់ និងទេយ្យទាន រួមមាន ៖ មី ទឹកក្រូច ទឹកបរិសុទ្ធ បច្ច័យ ទៅប្រគេនព្រះសង្ឃ និងក្រមាចែកជូនយាយជី តាជី ដែលកំពុងសំណាក់ធម៌ នៅក្នុងវត្តឫស្សី នៅភូមិរបងក្រាស់ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣។

❋ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តវណ្ណារាម (ហៅវត្តព្រៃទំនប់) នៅភូមិព្រៃទំនប់ ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ព្រមទាំងចូលរួមបច្ច័យសម្រាប់តម្កល់ទុកកសាងក្នុងវត្តមួយចំនួន នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៩ នៅវត្តខេត្តវ័ន (ហៅវត្តទួលអង្គុញ) ភូមិស្វាយសុខុម ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ព្រមទាំងចូលរួមបច្ច័យសម្រាប់តម្កល់ទុកកសាងក្នុងវត្តមួយចំនួន នាព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យឆ្លងចេតិយ និងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិក្រសាំងរលើង សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប នារសៀលថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១ នៅវត្តឥត្តប្បត្តបូរី (ហៅវត្តអង្គរតូចខាងត្បូង) និងបានចូលបច្ច័យបុណ្យមួយចំនួន នៅភូមិក្រវ៉ាន់ ស្រុកអង្គរធំ ខេត្តសៀមរាប នារសៀលថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១៤ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទ្រកោសា វត្តព្រះឥន្ទ្រកោសីយ៍ និងវត្តអង្គរខាងជើង ព្រមទាំងឧបត្ថម្ភថវិកាមួយជំនួនជូនតាជី យាយជី នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រះអង្គខ្មៅ ព្រមទាំងបានជូនថវិកាមួយចំនួនជូនតាជី យាយជី នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៣៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធី «យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក» ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារពិសេស និងជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅទីលានកីឡដ្ឋាន ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។



-ចូលរួមកិច្ចប្រជុំក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម (ក្រុម “ក”) នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣។

❈នារសៀលថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និង ឯកឧត្តម **ឈិត គីមយ៉ាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៥ នៃការបង្កើតទំនាក់ទំនងការទូតចិន-កម្ពុជា និងខួបអនុស្សាវរីយ៍លើកទី៧៤ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅ SUN & MOON Riverside Hotel រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិទួលរកា៣ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

❈នាថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **ប៊ុន ស៊ី** ម្ដាយបង្កើតរបស់ឯកឧត្តម **ភុក អាន** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដែលបានទទួលមរណភាពក្នុងជន្មាយុ





៨៦ឆ្នាំ ដោយជរាពាធ នៅផ្លូវលេខ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈ-កម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញសួរសុខទុក្ខលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ ដែលកំពុងសម្រាកព្យាបាលជំងឺ នៅគ្លីនិកអ៊ែរឆ្លីស រាជធានីភ្នំពេញ។

❈នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ លោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា លោក-ជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវ **ស៊ី ចាន់ណាថា** សមាជិកាគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ចឹក ហេង** សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ដែលកំពុងសម្រាកព្យាបាលជំងឺនៅព្រះរាជាណាចក្រថៃ៕

## ការទទួលពាក្យបណ្ដឹង

❈ក្នុងខែតុលា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន ៤ករណី៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធ-សភាបានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរ-សភាលើកទី១៤៧ (IPU-147) និងកិច្ចប្រជុំសមាគមអគ្គ-លេខាធិការសភាពិភពលោក នៅទីក្រុង Luanda ប្រទេស Angola៕



# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែកញ្ញា និងកំណត់ទិសដៅការងារខែតុលា ឆ្នាំ២០២៣




*ឯកឧត្តម អ៊ុំ សារឹទ្ធ ឯកឧត្តម ឡោក ឆាយ*

នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងលើកទិសដៅការងារសម្រាប់ខែតុលា ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានមានប្រសាសន៍ថា ខែកញ្ញាជាខែចុងក្រោយ នៃវិស្សមកាលរយៈពេល៣ខែរបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានបានផ្តោតការយកចិត្តទុកដាក់លើការផ្តល់សេវាលើមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់មុខងារតំណាង ដោយបានរៀបចំចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន១លើក ចុះបំពេញការងារជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការតាមបណ្តាខេត្តក្រុងចំនួន៧លើក និងអមដំណើរគណៈកម្មការជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរថ្នាក់ក្រោមជាតិ ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ។ចំពោះមុខងារសហប្រតិបត្តិការអន្តរជាតិ ក្នុងអំឡុងពេលសម្តេចប្រធានព្រឹទ្ធសភាបំពេញមុខងារជាប្រមុខរដ្ឋស្តីទី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំជំនួបសវនាការជាមួយនឹងភ្ញៀវជាតិ និងអន្តរជាតិបានដោយរលូន។





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២៣*

ឯកឧត្ដម **អ៊ុំ សារឹទ្ធ** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអង្គភាពពាក់ព័ន្ធទាំងអស់ ដែលបានផ្ដល់សេវាយ៉ាងល្អប្រសើរ និងឆ្លើយតបបានតាមសំណូមពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា។ ស្ថិតក្នុងអន្តរកាលឆ្លោះទៅបញ្ចប់នីតិកាលទី៤និងផ្ដើមនីតិកាលទី៥ ប្រកបដោយបរិយាបន្នហើយធានាបាននិរន្តរភាព អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តធ្វើបច្ចុប្បន្នភាពឯកសារគោលសំខាន់ៗផែនការសកម្មភាពការងារ ការកែសម្រួលរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង ការបូកសរុបសមិទ្ធផលការងាររបស់ព្រឹទ្ធសភានីតិកាលទី៤ ការបំពាក់សម្ភារៈ ការកសាងជួសជុល និងកែលម្អហេដ្ឋានរចនាសម្ព័ន្ធរូបវន្តនានាសម្រាប់ព្រឹទ្ធសភានីតិកាលទី៥។ការត្រៀមសព្វសារពើសម្រាប់ការងារខាងមុខ គឺជារឿងអាទិភាព ដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យត្រូវតែខិតខំជាអតិបរមាដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណសម្បត្តិសព្វយ៉ាង ទាំងទីកន្លែងធ្វើការ ធនធានសម្ភារៈបរិក្ខារ បច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុ មានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំបានទាន់ពេលវេលា ដូចការគ្រោងទុក។

សម្រាប់ខែតុលាខាងមុខនេះ ឯកឧត្ដមអគ្គលេខាធិការ-ព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាពីការត្រៀមសព្វសារពើ ពីព្រោះពេលវេលាកាន់តែលឿនទៅមុខ ដើម្បីសម្រេចផែនការយុទ្ធ-សាស្ត្រព្រឹទ្ធសភា ឌីជីថល និងបៃតង (២០២៤-២០៣០) ក្នុងបរិបទ នៃព្រឹទ្ធសភា នីតិកាលទី៥។

ការវិនិយោគបន្ថែមថ្មីៗ ដើម្បីបំពេញតម្រូវការមូលដ្ឋានសម្ភារៈបច្ចេកទេស បច្ចេកវិទ្យា បរិស្ថាន និងទីកន្លែងធ្វើការសម្រាប់នីតិកាលថ្មី គឺជាកិច្ចការពិសេស បន្ទាន់ និងចាំបាច់បំផុត។ ការផ្ទេរក្បាលម៉ាស៊ីនដឹកនាំ ទាំងរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល ទាមទារនូវការសម្របសម្រួលទាំងនយោបាយ រដ្ឋបាល បច្ចេកទេស ព្រមទាំងការចាត់តាំងឱ្យបានល្អ និងរលូន ក្នុងស្មារតីបើកទូលាយ និងសហ-ការប្រសើរបំផុត។ ការផ្លាស់ប្ដូរអាជីព មុខងារ និងទីកន្លែងធ្វើការនាដើមនីតិកាលនីមួយៗ ជារឿងធម្មតាក្នុងអាជីពសភា៕

(អត្ថបទ និងរូបភាព៖ លោក វង់ សុជាតិ)



*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា ឆ្នាំ២០២៣*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំនព្វមាសនិងកំណត់ទិសដៅការងារបន្ត ឆ្នាំ២០២៣




*ឯកឧត្តម ខេង សិទ្ធិគុណ* *ឯកឧត្តម អ៊ុំ សារឹទ្ធ* *ឯកឧត្តម ឡោក ឆាយ* *ឯកឧត្តម អោក បូរ៉ា*

នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំនព្វមាស និងលើកទិសដៅការងារបន្ត ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរយៈពេល៩ខែ ឆ្នាំ២០២៣នេះថា ឆ្លងតាមការវាយតម្លៃការអនុវត្តផែនការប្រតិបត្តិឆ្នាំ២០២៣ របស់គ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ការអនុវត្តការងារសម្រេចបានលទ្ធផលកើនឡើងលើមុខងារទាំង៥ ធៀបនឹងរយៈពេល៩ខែឆ្នាំ២០២២។ វឌ្ឍនភាពការងារទាំងអស់នេះ ជាសូចនាករនៃការគ្រប់គ្រង ដឹកនាំ និងការខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងការបំពេញការងារអស់ពីកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ប្រកបដោយភាពធន់លើគ្រប់ការដ្ឋានការងារ ស្របតាមផែនការយុទ្ធសាស្ត្រ (២០២១-២០៣០) សម្រាប់ការអភិវឌ្ឍព្រឹទ្ធសភា ឱ្យក្លាយជាសភាទំនើប។

ជាមួយនឹងលទ្ធផលសម្រេចបានក្នុងរយៈពេល៩ខែ ឆ្នាំ២០២៣ តម្រូវឱ្យថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបន្តខិតខំបន្ថែមទៀត ដើម្បីពង្រឹងពង្រីកការងារលើគ្រប់វិស័យ និងគ្រប់មុខសញ្ញាឱ្យបានបោះជំហានទៅមុខព្រមៗគ្នា ទន្ទឹមនឹងការខិតខំប្រមែប្រមូលការគាំទ្រពីសភាជាមិត្ត ដើម្បីគាំទ្រដល់ការចាប់ផ្ដើមនីតិកាលទី៥ នៃព្រឹទ្ធសភា។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ការឯកភាព សាមគ្គីភាព និងសហប្រតិបត្តិការគ្នាដ៏ល្អប្រពៃ គឺជាមូលដ្ឋានគ្រឹះនៃដំណើរឈានទៅមុខប្រកបដោយជោគជ័យរបស់ព្រឹទ្ធសភា។ ការងារបញ្ចប់នីតិកាលទី៤ និងការងារចាប់ផ្ដើមនីតិកាលទី៥ នៃព្រឹទ្ធសភាឱ្យបានល្អប្រសើរ គឺជាកាតព្វកិច្ចចាំបាច់បំផុត ដែលត្រូវប្រមូលផ្ដុំការខិតខំឱ្យសម្រេចបានទាន់ពេលវេលា គ្រប់មុខសញ្ញា និងគ្រប់វិស័យ៕

(អត្ថបទ និងរូបភាព៖ លោក វង់ សុជាតិ)





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំនព្វមាស និងកំណត់ទិសដៅបន្ត ឆ្នាំ២០២៣*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្ដីពីសភាបៃតង៖ តួនាទីសំខាន់របស់រដ្ឋបាលសភា




*ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា*

នារសៀលថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាតាមប្រព័ន្ធនិម្មិតស្ដីពី សភាបៃតង៖ តួនាទីរបស់រដ្ឋបាលសភា (Webinar on the Greener Parliaments: Role of Parliamentary Administrations) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

សិក្ខាសាលាតាមប្រព័ន្ធអនឡាញនេះ ប្រព្រឹត្តទៅក្រោមការសហការរៀបចំដោយសមាគមអគ្គលេខាធិការសភាពិភពលោក និងសហភាពអន្តរសភា IPU ក្នុងគោលបំណង ដើម្បីចែករំលែកបទពិសោធន៍ ឧត្តមានុវត្តន៍របស់សភា ពិសេសរដ្ឋបាលសភា ក្នុងការផ្សព្វផ្សាយ និងជំរុញដំណើរការការរៀបចំស្ថាប័ន និងការអនុវត្តប្រកបដោយនិរន្តរភាពបរិស្ថាននៅក្នុងសភាទូទាំងពិភពលោក។

ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភាបានចូលរួមចែករំលែកបទពិសោធន៍របស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំសភាបៃតង និងសភាអេឡិចត្រូនិក ក្នុងការឆ្លើយតបទៅនឹងសារសំខាន់ នៃតួនាទីរដ្ឋបាលសភា ក្នុងការរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យនានាបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ។

ពាក់ព័ន្ធនឹងការងារនេះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានបញ្ជាក់ថា ព្រឹទ្ធសភាកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ និងបានគិតគូរកសាងផែនការអភិវឌ្ឍន៍រយៈពេលវែង (២០២៤-២០៣០) របស់ខ្លួន ផ្ដោតជាសំខាន់លើសភាបៃតង និងសភាអេឡិចត្រូនិក។ ជាមួយគ្នានេះព្រឹទ្ធសភាកម្ពុជាក៏បាន នឹងកំពុងអនុវត្តផែនការនេះ ដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយហានិភ័យ នៃការបង្កគ្រោះថ្នាក់ដល់ការប្រែប្រួលអាកាសធាតុ មានដូចជា៖

-ការបំពាក់អំពូលភ្លើងដើរដោយថាមពលពន្លឺព្រះអាទិត្យសម្រាប់បំភ្លឺក្នុងបរិវេណព្រឹទ្ធសភានាពេលយប់
-ការបង្កើតមាតិកាឌីជីថល កម្មវិធីទូរស័ព្ទចល័ត សម្រាប់ចែករំលែកព័ត៌មាន
-ការបង្កើតបណ្ណាល័យអេឡិចត្រូនិក និងពង្រឹងមាតិកាផ្សេងៗទៀត
-ការរៀបចំផែនការបង្កើតប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិកសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-ការដាំដើមឈើ និងបង្កើតសួនច្បារបៃតង
-ការប្រើប្រាស់រថយន្តបោសសម្អាតអគ្គិសនី ដើម្បីសម្អាត និងប្រមូលសំរាមក្នុងបរិវេណព្រឹទ្ធសភា
-ការប្រើប្រាស់សំរាមជាជី
-ការរៀបចំផែនការសាងសង់ប្រព័ន្ធកែច្នៃទឹកកខ្វក់ឡើងវិញដែលនឹងដាក់ស្តុកទឹកសម្រាប់ស្រោចសួនច្បារ និងដើមឈើក្នុងបរិវេណព្រឹទ្ធសភា
-ការមិនប្រើប្រាស់ប្លាស្ទិកក្នុងបរិវេណព្រឹទ្ធសភា។

ឆ្លៀតឱកាសនោះដែរ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបង្ហាញអំពី បញ្ហាប្រឈមមួយចំនួនដែលព្រឹទ្ធសភាកម្ពុជាបាន នឹងកំពុងជួបប្រទះក្នុងការអនុវត្តផែនការខាងលើនេះ។ បន្ថែមពីនេះ ឯកឧត្តមក៏បានបង្ហាញអំពីការស្វាគមន៍ចំពោះការចែករំលែកបទពិសោធន៍របស់ឯកឧត្តម លោកជំទាវជាអគ្គលេខាធិការសភា នៃប្រទេសនានា ដែលធ្លាប់បានប្រតិបត្តិលើការងារពាក់ព័ន្ធទាំងនេះ ចូលរួមសហការគ្នាដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការការពារភពផែនដីយើង សម្រាប់យើងទាំងអស់គ្នា និងសម្រាប់ប្រជាជាតិជំនាន់ក្រោយផងដែរ៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គឹម សិទ្ធី)



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការកំណត់រចនាសម្ព័ន្ធ និងមុខតំណែងគ្រប់គ្រង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមចាប់ពីប្រធាននាយកដ្ឋានឡើង។



❈នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពី ការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់អនុវត្តន៍នាពេលខាងមុខ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា អគ្គនាយករង នៃអគ្គនាយកដ្ឋានទាំង៥ និងអគ្គាធិការ ព្រមទាំងអង្គភាពជំនាញពាក់ព័ន្ធ។



❈នារសៀលថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាផ្តល់យោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំរួមស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក Jean Lestienne ទីប្រឹក្សាតំណាងឱ្យសហគមន៍បារាំងប្រចាំនៅបរទេស និងជាទីប្រឹក្សាស្ម័គ្រចិត្តអមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ ឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង នៅប្រទេស Angola។




❈នាព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្ដម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាគោលការណ៍ស្ដីពី ការបង្កើនកម្រិតប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាជាស្ត្រី ក្នុងអំឡុងពេលមានផ្ទៃពោះរហូតដល់កូនអាយុក្រោម២ឆ្នាំ និងសោធននិវត្តន៍បុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ឯកឧត្ដម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី កំណែ-ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងវគ្គបណ្ដុះបណ្ដាលស្ដីពី អភិបាលកិច្ចល្អ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១១៩នាក់។



❈នារសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ ២០២៣ ឯកឧត្ដម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ចការ-សភា (ជំហានទី៨) នៅសាលសិក្ខាសាលាខាងជើង វិមាន-ព្រឹទ្ធសភា ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥៦នាក់។



❈ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ឯកឧត្ដម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកម្មវិធីធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ជូនដល់ឯកឧត្ដម **ខេង សិទ្ធិគុណា** និងឯកឧត្ដម **សោភ ម្ញ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា ដែលទើបតែងតាំងថ្មី នៅសាលប្រជុំពិសេសក្រោម វិមាន-ព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❋នាព្រឹកថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការដំឡើងមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាអំពីនីតិវិធី និងបែបបទចុះ-ដំឡើង និងស្នើសុំចេញសេចក្ដីជូនដំណឹងស្ដីពី ការដំឡើងមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធ-សភា។



❋នារសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្ដីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី បែបបទពិធីការរបស់ស្ថាប័ន ការកាន់កម្មវិធី និងការងារផ្សេងៗ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៥០នាក់។



❋នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ គណៈប្រតិភូ-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ប្រាក់ វណ្ណឌី** នាយករងខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅផ្ទះលេខ២០ ផ្លូវ៤៦២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



❋នាព្រឹកថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ បានអញ្ជើញធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានស្រាវជ្រាវ ជូនដល់មន្ត្រីរាជការដែលជាសិក្ខាកាមចូលរៀនវគ្គបណ្ដុះបណ្ដាលស្ដីពី កិច្ច-ការសភា (ជំហានទី៨) នៅសាលសិក្ខាសាលាខាងជើង-ព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❋នាព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **ទេព ចាន់អុនឌុធីរក្ស** អញ្ជើញធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ជូនដល់មន្ត្រីរាជការដែលជាសិក្ខាកាមចូលរៀនវគ្គបណ្ដុះ-បណ្ដាលស្ដីពី កិច្ចការសភា (ជំហានទី៨) នៅសាលសិក្ខា-សាលាខាងជើងព្រឹទ្ធសភា។



❋នារសៀលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ឯកឧត្តម **ឈឹម សុទ្ធគុណា** អគ្គនាយក នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងលោក Wu Chuanbing ទីប្រឹក្សាស្ថានទូត នៃសាធារណរដ្ឋប្រជាមានិចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស កណ្ដាល វិមានព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៩:០០នាទី លោកជំទាវ **រត្ន ឆវីលក្ខណ៍** ប្រធានគណៈ-កម្មការត្រួតពិនិត្យ និងជាអគ្គាធិការ នៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា បានប្រជុំពិភាក្សាការងារជាមួយអង្គភាពគ្រប់គ្រង មូលនិធិសង្គមកិច្ចមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធ-សភា ដឹកនាំដោយឯកឧត្តម **កែវ ចាន់ណា** អគ្គនាយក-ព័ត៌មាន និងទំនាក់ទំនងសាធារណៈ និងជាប្រធានអង្គភាព គ្រប់គ្រងមូលនិធិសង្គមកិច្ចមន្ត្រីរាជការ នៃអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សាលើរបាយការណ៍ ស្ដីពី ប្រតិបត្តិការគ្រប់គ្រងចំណូលចំណាយ ចរន្តសាច់ប្រាក់ ប្រចាំនព្វមាស (៩ខែ) ឆ្នាំ២០២៣ របស់អង្គភាពគ្រប់គ្រង មូលនិធិសង្គមកិច្ចមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធ-សភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❋នាព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៩:៤៥នាទី លោកជំទាវ **រត្ន ឆវីលក្ខណ៍** ប្រធានគណៈ-កម្មការត្រួតពិនិត្យ និងជាអគ្គាធិការ នៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា បានប្រជុំពិភាក្សាការងារជាមួយនឹងអង្គភាព គ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទា-វិជ្ជាជីវៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយ លោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយក-ដ្ឋានស្រាវជាវ និងជាប្រធានអង្គភាពគ្រប់គ្រងបេឡាសោ-ធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់-ក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ គណៈកម្មការមូលដ្ឋាន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃសមាគមសង្គហៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ បានប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី៣ និងទិសដៅបន្ត ឆ្នាំ២០២៣ និងពិនិត្យលើបញ្ហាការងារផ្សេងៗ ក្រោមការដឹកនាំអង្គប្រជុំដោយឯកឧត្តម **លី រិទ្ធី** ប្រធានគណៈកម្មការមូលដ្ឋានសមាគមសង្គហៈមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៅសាលប្រជុំពិសេសក្រោមវិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម **លី ឡេង** នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា តំណាងរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា បានអញ្ជើញនាំយកសម្ភារៈ ឧបករណ៍សម្រាប់បម្រើឱ្យការងារថែរក្សាសុខភាពប្រជាពលរដ្ឋទៅផ្ដល់ជូនមណ្ឌលសុខភាពជាច និងសាលាឃុំជាច នៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង និងមន្ទីរពេទ្យបង្អែកពញាក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី២ ខែតុលា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកកម្រងផ្កា និងបច្ច័យរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ទៅចូលរួមរំលែកទុក្ខបុណ្យសព ឧបាសិកា **ម៉ុន ស៊ី** ម្ដាយបង្កើតរបស់ឯកឧត្តម **កុក អាន** សមាជិកព្រឹទ្ធសភា។




❈នាព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ ខុទ្ទកាល័យឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ធន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តអូរសោម ស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្នុងឱកាសពិធីបុណ្យកាន់បិណ្ឌវេនទី៩ និងបាននាំយកអំណោយរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត ចែកជូនគ្រួសារក្រីក្រចំនួន៥ គ្រួសារផងដែរ។



